**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន**

លេខ : ៣៤ សកអ

# សារាចរ

***

**ជំរាបមក**

**លោកនាយកក្រុមហ៊ុនកាត់ដេរ គ្រប់ក្រុមហ៊ុនទាំងអស់ក្នុងព្រះរាជាណាចក្រកម្ពុជា**

**កម្មវត្ថុ :** ការអនុវត្តន៍ច្បាប់ការងារ ស្តីពីសន្តិសុខ និងអនាម័យការងារ ចំពោះកម្មករ និយោជិត ការគោរពសិទ្ធិ កិត្តិយសរបស់កម្មករ និយោជិត ។

ខ្ញុំសូមជំរាបជូនលោកនាយកក្រុមហ៊ុនកាត់ដេរទាំងអស់បានជ្រាបថា កន្លងទៅក្រុមអធិការកិច្ចការងាររបស់ក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន បានចុះទៅធ្វើអធិការកិច្ចការងារនៅតាមរោងចក្រទាំងឡាយរបស់ក្រុមហ៊ុន ដើម្បីណែនាំឲ្យនិយោជកអនុវត្តឲ្យបានខ្ជាប់ខ្ជួននូវច្បាប់ការងារ សំដៅជួយឲ្យក្រុមហ៊ុនប្រព្រឹត្តទៅបានស្របទឹងច្បាប់ផង និងរក្សាឲ្យបានល្អនូវល័ក្ខខ័ណ្ឌការងារដែលនិយោជក និងកម្មករនិយោជិតត្រូវតែគោរពគ្នាទៅវិញទៅមកផង ដូចជាការកំណត់ប្រាក់ឈ្នួល ការបើកប្រាក់ឈ្នួល ការកាត់ប្រាក់ឈ្នួល ការឈប់សំរាកប្រចាំសប្តាហ៍ ការឈប់សំរាកថ្ងៃបុណ្យដោយទទួលប្រាក់ឈ្នួល ការឈប់សំរាកដោយមានជម្ងឺ ការឈប់សំរាកពេលសំរាលកូន ការឈប់ដោយគ្រោះថ្នាក់ការងារ ការឈប់សំរាកប្រចាំឆ្នាំ ការងារលើសម៉ោង ការងារពេលយប់ ការងារសំរាប់កុមារ ការងារសំរាប់ស្ត្រី ការបញ្ឈប់ពីការងារ ការពិនិត្យព្យាបាលពេលមានជម្ងឺ ឬពេលមានគ្រោះថ្នាក់ការងារ ព្រមទាំងសន្តិសុខ និងអនាម័យពលកម្មរបស់កម្មករ និយោជិតផង ។

ការណែនាំនេះ ក្រុមអធិការកិច្ចការងារបានធ្វើចំពោះក្រុមហ៊ុនទាំងអស់ជាង ៥០ក្រុមហ៊ុនហើយ គិតទាំងក្រុមហ៊ុនដែលនៅក្នុងសមាគមនិយោជកផ្នែកកាត់ដេរ និងក្រុមហ៊ុនដែលមិននៅក្នុងសមាគមនេះផង ។ ក្រុមហ៊ុនទីមួយៗ ក្រុមអធិការកិច្ចបានណែនាំម៉ោងពេលណាស់ពី ពីរដងដែរ ។

ការខិតខំរបស់មន្ត្រីក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន ពុំទាន់ទទួលបានលទ្ធផលជាទីគាប់ចិត្តនៅឡើយទេ ។ ក្រុមហ៊ុនខ្លះអនុវត្តបានមួយចំនួន ក្រុមហ៊ុនខ្លះទៀតមិនទាន់អនុវត្តតាមនៅឡើយ ។

ដោយសារក្រុមហ៊ុនមិនព្រមអនុវត្តតាមច្បាប់ការងារនេះហើយ បានជាបញ្ហាមួយចំនួនបានកើតឡើងដោយមានការទាមទារពីកម្មករ និយោជិត សុំឲ្យនិយោជកអនុវត្តតាមច្បាប់ការងារ ។ ក្រុមហ៊ុនណាដែលមិនបានអនុវត្តតាមការណែនាំរបស់មន្ត្រីអធិការកិច្ចការងារចាប់ពី ៥ដងឡើងទៅ ក្រសួងបានធ្វើការដាក់ពិន័យ ឬបញ្ជូនទៅតុលាការតាមច្បាប់ការងាររួចអស់ហើយ ។

គ_ សន្តិសុខ និងអនាម័យការងារ :

ក្រសួងបានណែនាំគ្រប់ក្រុមហ៊ុនរួចហើយ អំពីសន្តិសុខ និងអនាម័យការងាររបស់កម្មករ និយោជិត ពិតទាំងពន្លឺ សម្លេង ធាតុអាកាស ចូលក្នុងកន្លែងធ្វើការ ការរៀបចំប្រអប់សង្គ្រោះ គិលានដ្ឋាន ទារកដ្ឋាន បន្ទប់បំបៅកូន ទ្វារ និងច្រកចេញពេលមានអាសន្នដូចជាអគ្គីភ័យជាដើម បង្គន់សំរាប់នារី និងបង្គន់សំរាប់បុរស ការធ្វើដំណើរបន្ថែម ។ល។

ការចាក់សោរទ្វារ ឬដាក់គន្លឹះទ្វារនៅម៉ោងធ្វើការ ត្រូវហាមឃាត់ជាដាច់ខាត ព្រោះបើសិនជាមានអគ្គីភ័យ ឬគ្រោះអាសន្នផ្សេងៗទៀតកើតឡើង កម្មករ និយោជិតនឹងទទួលរងគ្រោះថ្នាក់ដល់អាយុជីវិត ដោយចេញមិនរួចពីកន្លែងធ្វើការ ។

អាស្រ័យហេតុដូចបានជំរាបជូនខាងលើនេះ ក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន សូមឲ្យគ្រប់នាយកក្រុមហ៊ុនកាត់ដេរទាំងអស់អនុវត្តឲ្យបានខ្ជាប់ខ្ជួន និងជាបន្ទាន់នូវចំណុចណាដែលក្រុមហ៊ុនរបស់លោកមិនទាន់បានអនុវត្តតាមប្រកាសទាំងឡាយរបស់ក្រសួង ព្រមទាំងសេចក្តីសំរេចដែលបានព្រមព្រៀងគ្នាពេលការចរចាជាសមូហភាព និង តាមការណែនាំរបស់មន្ត្រីក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន ដែលបានចុះធ្វើអធិការកិច្ច ។

មន្ត្រីអធិការកិច្ចការងាររបស់ក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន ត្រៀមខ្លួនជាស្រេចនឹងផ្តល់នូវការពន្យល់ ឬណែនាំបន្ថែមចំពោះចំណុចណាដែលក្រុមហ៊ុនមិនទាន់បានយល់ច្បាស់ ដើម្បីឈានទៅអនុវត្តឲ្យបានល្អតាមច្បាប់ការងារ និង សារាចរណែនាំនេះ ។

ភ្នំពេញ ថ្ងៃទី ០៥ ខែ មករា ឆ្នាំ ១៩៩៧

រដ្ឋលេខាធិការ

ស៊ុយ សែម

ចម្លងជូន :

- ព្រះរាជលេខាធិការដ្ឋានព្រះមហាក្សត្រ
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចក្រុមព្រះនាយករដ្ឋមន្ត្រីទី១
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រីទី២
- ក្រសួងព័ត៌មាន " ដើម្បីផ្សព្វផ្សាយទូលំទូលាយ "
- គ្រប់ប្រព័ន្ធឃោសនា ផ្សព្វផ្សាយ
- ក្រសួងពាណិជ្ជកម្ម
- សភាពាណិជ្ជកម្មរាជធានីភ្នំពេញ
- គ្រប់ក្រុមហ៊ុនកាត់ដេរសំលៀកបំពាក់
- រាជកិច្ច
- ឯកសារ . កាលប្បវត្តិ